**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខៈ ០៣៩ រស

# សេចក្តីសម្រេច

# ស្តីពី

# របបប្រាក់សោធននិវត្តន៍ នៃតំណាងរាស្ត្រ

## ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា

-បានឃើញលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំ រដ្ឋសភានាសម័យប្រជុំលើកទី៤ នីតិកាលទី ៣ នៃរដ្ឋសភា កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦

-បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៦/០២៩ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ

-បានឃើញការឯកភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នាសម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍កាលពីថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០០៧

## សម្រេច

## ជំពូកទី១

## ប្រាក់សោធននិវត្តន៍

**ប្រការ១ :** តំណាងរាស្ត្រទទួលប្រាក់សោធននិវត្តន៍បាន លុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម :

-ជាតំណាងរាស្ត្រ គិតចាប់ពីឆ្នាំ១៩៩៣ មក

-មានអាយុចាប់ពី៦០ឆ្នាំឡើង

-មិនបានទទួលប្រាក់សោធននិវត្តន៍ពីស្ថាប័នណាមួយរបស់រដ្ឋទេ ។

**ប្រការ២ :** ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនម្នាក់ៗត្រូវផ្អែកលើប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងនៃឆ្នាំចុងក្រោយរបស់តំណាងរាស្ត្រម្នាក់ៗ ដោយគិតទាំងឋានៈមុខងារផងដែរ កំណត់ស្មើមួយរយភាគរយ ។

**ប្រការ៣ :** ប្រាក់សោធននិវត្តន៍ប្រចាំខែត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅ :

-ពី ១ឆ្នាំ ដល់ ៣ឆ្នាំ ទទួលបានសន្ទស្សន៍ 0.៥ %

-លើសពី ៣ឆ្នាំ ដល់ក្រោម ៦ឆ្នាំ ទទួលបានសន្ទស្សន៍ ១ %

-ពី ៦ឆ្នាំ ដល់ក្រោម ១១ឆ្នាំ ទទួលបានសន្ទស្សន៍ ២ %

-ពី ១១ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ទទួលបានសន្ទស្សន៍ ៣ %

-ពី ១៦ឆ្នាំ ឡើងទៅ ទទួលបានសន្ទស្សន៍ ៤ %

-ចំពោះតំណាងរាស្ត្រក្នុងតំណែងបីអាណត្តិបន្តបន្ទាប់គ្នា ទទួលបានសន្ទស្សន៍ ៤ %

ការគណនាប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម :

| ប្រាក់សោធននិវត្តន៍ប្រចាំខែ = ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងនៃឆ្នាំចុងក្រោយ X សន្ទស្សន៍ |
|---|

ប្រាក់សោធននិវត្តន៍ប្រចាំខែអាចប្រែប្រួលបានទៅតាមប្រាក់បំណាច់និងប្រាក់ឧបត្ថម្ភគ្រប់យ៉ាងនៃថវិកាប្រចាំឆ្នាំចុងក្រោយ ដោយមិនគិតជានិវត្តជនមុន ឬ និវត្តជនក្រោយឡើយ ។

**ប្រការ៤ :** និវត្តជននៅពេលជាប់ឆ្នោតជាថ្មីជាតំណាងរាស្ត្រ ប្រាក់សោធននិវត្ត មិនត្រូវបានបើកផ្តល់ទៀតទេ ។ សាមីជនត្រូវបើកប្រាក់បំណាច់ជាតំណាងរាស្ត្រជាធម្មតា ហើយនៅពេលចប់អាណត្តិទើបសាមីជនបើកប្រាក់សោធននិវត្តវិញសាជាថ្មី ។

**ប្រការ៥ :** របៀបគិតអតីតភាពការងារ របស់តំណាងរាស្ត្រ គឺមានដូចតទៅ :

-មានអតីតភាព ចាប់ពី១៦ថ្ងៃឡើងទៅ ត្រូវគិតស្មើ១ខែ ។

-មានអតីតភាព ចាប់ពី៦ខែឡើងទៅ ត្រូវគិតស្មើ១ឆ្នាំ ។

## ជំពូកទី២

## ភារកិច្ច និងសមត្ថកិច្ចគ្រប់គ្រងប្រាក់សោធននិវត្តន៍

**ប្រការ៦ :** ជារៀងរាល់ឆ្នាំ អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវរៀបចំគំរោងផែនការស្ថិតិ និងថវិកាប្រាក់សោធននិវត្តន៍ និងប្រាក់ធានារ៉ាប់រងសង្គមសំរាប់តំណាងរាស្ត្រ ដែលគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តននិងទទួលមរណភាព ដោយអនុលោមតាមប្រការ ៣១ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។

**ប្រការ៧ :** ការបើកប្រាក់សោធននិវត្តន៍ និងប្រាក់ធានារ៉ាប់រងសង្គមជាសមត្ថកិច្ចរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា ។៚

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**ប្រការ៨ :** គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា និងអគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ.ថ្ងៃទី.៨.១.ខែ.មិថុនា.ឆ្នាំ២០០៧

**ប្រធានរដ្ឋសភា**

**ហេង សំរិន**

<u>ចម្លងជូន</u> :

-ខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា

-ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ រដ្ឋសភា

-ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ រដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សមាជិក សមាជិកា រដ្ឋសភា

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

- កាលប្បវត្តិ-ឯកសារ